២០១៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

Ministry of Industry & Handicraft

លេខ: ៨០៦ MIH / 2015

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង

យោងតាមស្ថានភាពជាក់ស្តែងរបស់អាជីវករ ក្រុមហ៊ុន ដែលកំពុងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតទាំងអស់ ក្រសួងឧស្សាហកម្ម និងសិប្បកម្មមានកិត្តិយស សូមជម្រាបជូនដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ឲ្យបានជ្រាបថា៖ ដើម្បីជួយសម្រួលដល់អាជីវករ ក្រុមហ៊ុន ដែលកំពុងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ក្នុងការបំពេញបែបបទស្នើសុំបន្តប្រកាសអនុញ្ញាត ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានសម្រេចអនុញ្ញាតឲ្យ អាជីវករ ក្រុមហ៊ុន ដែលកំពុងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត អាចដាក់ពាក្យស្នើសុំបន្តប្រកាសអនុញ្ញាតដែលមានសុពលភាពរយៈពេល ៣ ឆ្នាំចុងក្រោយ គិតចាប់ពីថ្ងៃដែលចុះហត្ថលេខាតទៅ ដោយថ្លៃលក់ត្រូវតែទាបជាងមុន ហើយមិនគិតថ្លៃមិនប្រើប្រាស់ទឹក (Minimum Charge)។ មុនពេលដែលប្រកាសអនុញ្ញាតបន្តនេះអស់សុពលភាព អាជីវករ ក្រុមហ៊ុន ចាំបាច់ត្រូវបំពេញបែបបទស្នើសុំបន្ត ប្រកាសអនុញ្ញាតជាថ្មីទៀតតាមនីតិវិធីដូចមានចែងក្នុងប្រកាសលេខ ៤៦១ MIH/2014 ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាដាច់ខាត។ ម្យ៉ាងវិញទៀត ប្រសិន បើអាជីវករ ក្រុមហ៊ុន នៅតែមានបំណងដាក់ពាក្យស្នើសុំបន្តប្រកាសអនុញ្ញាតដែលមានសុពលភាពរយៈពេល ២០ឆ្នាំ តាមនីតិវិធីនៃប្រកាសលេខ៤៦១ MIH/2014 ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នោះ អាជីវករ ក្រុមហ៊ុន ក៏អាចដាក់ពាក្យបានតាមធម្មតាដែរ។

សេចក្តីជូនដំណឹងនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ចម ប្រសិទ្ធ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីម៉ែល: mih.smcabinet@gmail.com